ក្រសួងមុខងារសាធារណៈ

គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

# កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨

ដោយ លេខាធិការដ្ឋាននៃ
គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

# មាតិកា

ជំពូកទី១៖ សេចក្តីផ្តើម

ជំពូកទី២៖ កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨

ជំពូកទី៣៖ យន្តការគាំទ្រ និងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិ

ជំពូកទី៤៖ ប្រភពថវិកា និង ធនធានហិរញ្ញវត្ថុ

ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន

# ជំពូកទី១៖ សេចក្តីផ្តើម

១.១ អ្វីទៅជាកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ

១.២ សមិទ្ធផលដែលសម្រេចបាន និងទិសដៅបន្តការងារកែទម្រង់

១.៣ បញ្ហាប្រឈមក្នុងរដ្ឋបាលសាធារណៈបច្ចុប្បន្ន

# ជំពូកទី១៖ សេចក្តីផ្តើម

## ១.១ អ្វីទៅជាកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ

- កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ជាកម្មវិធីរបស់រាជរដ្ឋាភិបាល រួមជាមួយនឹងផែនការសកម្មភាពដែលត្រូវអនុវត្តពីឆ្នាំ២០១៥-២០១៨
- ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធទាំងអស់ ផ្អែកលើមូលដ្ឋាន៖ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ (២០១៤-២០១៨) គោលនយោបាយសេវាសាធារណៈ ធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ សមិទ្ធផលដែលសម្រេចបាន រួមផ្សំជាមួយនឹងបញ្ហាប្រឈម និងការបន្តអនុវត្តផែនការសកម្មកែទម្រង់ដទៃទៀត
- កិច្ចប្រជុំអន្តរក្រសួង ដៃគូអភិវឌ្ឍក្នុងក្រុមការងារបច្ចេកទេស គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងបានទទួលការអនុម័តជាផ្លូវការពីកិច្ចប្រជុំពេញ គណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥។

# ជំពូកទី១៖ សេចក្តីផ្តើម

## ១.២ សមិទ្ធផលដែលសម្រេចបាន និងទិសដៅបន្តការងារកែទម្រង់

- ១៩៩៣-១៩៩៨៖ ការអនុវត្តគោលនយោបាយផ្សះផ្សានិងបង្រួបបង្រួមជាតិ
- ១៩៩៩-២០០៣៖ ការពង្រឹងគ្រឹះនៃការគ្រប់គ្រងមុខងារសាធារណៈ
- ២០០៤-២០០៨៖ ការអនុវត្តកំណែទម្រង់ស៊ីជម្រៅ
- ២០០៨-២០១២៖ ការបន្តអនុវត្តកំណែទម្រង់ស៊ីជម្រៅ
- ២០១៣-២០១៨៖ ការបន្តអនុវត្តកំណែទម្រង់ស៊ីជម្រៅដើម្បីប្រសិទ្ធភាព
  - ២០១៣-២០១៤៖ សម្រេចបានសមិទ្ធផលសំខាន់ៗជាច្រើន
  - ២០១៥-២០១៨៖ ទិសដៅការងារជាអាទិភាពដែលត្រូវអនុវត្តបន្ត។

រូបភាពទី១.១ : គំនូសបំព្រួញយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣



# ជំពូកទី១៖ សេចក្ដីផ្ដើម

## ១.៣ បញ្ហាប្រឈមក្នុងរដ្ឋបាលសាធារណៈបច្ចុប្បន្ន

**ទី១.** នីតិវិធីមួយចំនួនក្នុងការផ្ដល់សេវាសាធារណៈនៅមានភាពស្មុគស្មាញ ប្រមូលផ្ដុំការិយាធិបតេយ្យ ទន្ទឹមនេះ ការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាក្នុងរដ្ឋបាលសាធារណៈនៅមានកម្រិត ហើយការរៀបចំនិង ការដាក់ឱ្យអនុវត្តមួយចំនួនមានលក្ខណៈដាច់ដោយដុំ មិនមានលក្ខណៈជាប្រព័ន្ធរួម។

**ទី២.** រំហូរការងារនិងទំនាក់ទំនងផ្ទៃក្នុងនៅតាមក្រសួង ស្ថាប័ន និងរវាងក្រសួង ស្ថាប័ន និងស្ថាប័ន នៅមិនទាន់ដំណើរការដោយបណ្ដាញតភ្ជាប់គ្នាប្រកបដោយប្រសិទ្ធភាពខ្ពស់ និងមានភាពរលូននៅឡើយ។

**ទី៣.** យន្តការ និងប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃគុណភាពនៃសេវាសាធារណៈមិនទាន់បានដាក់ឱ្យដំណើរការប្រកបដោយប្រសិទ្ធភាព។

# ជំពូកទី១៖ សេចក្តីផ្តើម

## ១.៣ បញ្ហាប្រឈមក្នុងរដ្ឋបាលសាធារណៈបច្ចុប្បន្ន

**ទី៤.** ការគ្រប់គ្រងនិងការអភិវឌ្ឍអាជីពរបស់មន្ត្រីរាជការ មិនទាន់ត្រូវបានរៀបចំជាប្រព័ន្ធប្រកបដោយប្រសិទ្ធភាពនិងមិនទាន់មានការរៀបចំការពិពណ៌នាអំពីមុខតំណែងឱ្យបានច្បាស់លាស់នៅឡើយ។

**ទី៥.** សមត្ថភាពធនធានមនុស្សនិងស្ថាប័ននៅមានកម្រិតក្នុងការឆ្លើយតបទៅនឹងសេចក្តីត្រូវការ របស់ប្រជាពលរដ្ឋ ពិសេសនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ទី៦.** ប្រព័ន្ធបៀវត្សមិនទាន់ឆ្លើយតបនឹងគោលការណ៍សមធម៌ ប្រសិទ្ធភាព សង្គតិភាពក្នុងនោះ គម្លាតបៀវត្សរបស់មន្ត្រីរាជការស៊ីវិលនៅមានកម្រិតខ្ពស់ ប្រព័ន្ធបៀវត្សរបស់កងកម្លាំងប្រដាប់អាវុធ និងមន្ត្រីរាជការស៊ីវិលមិនទាន់មានសង្គតិភាពនឹងគ្នា។

# ជំពូកទី២៖ កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨

២.១ ចក្ខុវិស័យ

២.២ គោលបំណង

២.៣ គោលដៅ

២.៤ យុទ្ធសាស្ត្រ

២.៥ យន្តការគាំទ្រការអនុវត្ត (បញ្ចូលទៅក្នុងជំពូកទី ៣)

២.៦ ផែនការសកម្មភាព

# ជំពូកទី២៖ កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨

## ២.១ ចក្ខុវិស័យ

"ប្រែក្លាយរដ្ឋបាលសាធារណៈឲ្យទៅជាអ្នកផ្តល់សេវាដ៏មានប្រសិទ្ធភាព និងជាដៃគូអភិវឌ្ឍដែលអាចជឿទុកចិត្តបាន សំដៅបម្រើប្រជាជនពលរដ្ឋឲ្យកាន់តែល្អប្រសើរឡើង"។

## ២.២ គោលបំណង

**ទី១-សេវាសាធារណៈ**ប្រកបដោយគុណភាព មានភាពសាមញ្ញ ប្រសិទ្ធភាព ភាពអាចជឿទុកចិត្តបាន ភាពឆាប់រហ័ស ឆ្លើយតបទាន់ពេលវេលាទៅនឹងសេចក្តីត្រូវការ មានភាពងាយស្រួល និង មានការចូលរួមពីអ្នកប្រើប្រាស់សេវា។

# ជំពូកទី២៖ កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨

## ២.២ គោលបំណង

**ទី២-ការគ្រប់គ្រងនិងការអភិវឌ្ឍមន្ត្រីរាជការស៊ីវិល** ឲ្យកាន់តែមានសមត្ថភាព ភាពស្វាហាប់ ប្រសិទ្ធភាព និងភាពជឿទុកចិត្តក្នុងការផ្តល់សេវាសាធារណៈ ដោយប្រកាន់ភ្ជាប់នូវវប្បធម៌សេវាសាធារណៈ ឆន្ទៈម្ចាស់ការ ភក្តីភាព និងមនសិការវិជ្ជាជីវៈ។

**ទី៣-ប្រព័ន្ធបៀវត្ស** ដែលធានាបាននូវសមធម៌ បង្កើនផលិតភាព និងប្រសិទ្ធភាពការងារ ព្រមទាំងធានាបាននូវសង្គតិភាពរវាងក្របខណ្ឌមន្ត្រីរាជការស៊ីវិល និងក្របខណ្ឌកងកម្លាំងប្រដាប់អាវុធ។

# ជំពូកទី២៖ កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨

## ២.៣ គោលដៅ

### ២.៣.១ សេវាសាធារណៈ

- ធានាភាពងាយស្រួលក្នុងការទទួលយកសេវាទៅប្រើប្រាស់
- ផ្តល់សេវាដែលផ្តោតទៅលើសេចក្តីត្រូវការជាក់ស្តែងរបស់អ្នកប្រើប្រាស់សេវា
- ផ្តល់សេវាឲ្យចំទីកន្លែងដែលមានសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់សេវា
- លើកកម្ពស់តម្លាភាព និងការទទួលខុសត្រូវក្នុងការផ្តល់សេវា
- កែលំអគុណភាព និងប្រសិទ្ធភាពក្នុងការផ្តល់សេវា។

# ជំពូកទី២៖ កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨

## ២.៣ គោលដៅ

### ២.៣.២ ការគ្រប់គ្រង និងការអភិវឌ្ឍន៍ធនធានមនុស្ស

- រៀបចំតួនាទី ភារកិច្ច របៀបគ្រប់គ្រង និងចាត់ចែងការងារឱ្យមានភាពច្បាស់លាស់
- គ្រប់គ្រងជំនាញនិងចំនួនមន្រ្តីឱ្យឆ្លើយតបទៅនឹងសេចក្តីត្រូវការ
- លើកកម្ពស់គុណផលនិងការទទួលខុសត្រូវរបស់មន្ត្រីរាជការស៊ីវិល
- អភិវឌ្ឍសមត្ថភាពការងាររបស់មន្ត្រីរាជការស៊ីវិល
- ពង្រឹងសីលធម៌និងវិន័យមន្ត្រីរាជការស៊ីវិល។

# ជំពូកទី២៖ កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨

## ២.៣ គោលដៅ

### ២.៣.៣ ប្រព័ន្ធបៀវត្ស

- រៀបចំប្រព័ន្ធបៀវត្សដែលធានានូវសមធម៌ដោយបង្រួមគម្លាតបៀវត្សអតិប្បរមា និង អប្បបរមា
- ធានាបើកផ្តល់ប្រាក់បៀវត្សជូនមន្ត្រីរាជការទាន់ពេលវេលា ដល់ដៃ និងគ្រប់ចំនួន
- ប្រព័ន្ធបៀវត្សដែលផ្តល់ការលើកទឹកចិត្តផ្អែកលើសមិទ្ធិកម្ម ព្រមទាំងគាំទ្រដល់ វិស័យអាទិភាពរបស់រាជរដ្ឋាភិបាល ដូចជា វិស័យអប់រំ និងសុខាភិបាល
- កែលំអរចនាសម្ព័ន្ធនៃបៀវត្ស ដើម្បីធានាសង្គតិភាពរវាងបៀវត្សមន្ត្រីរាជការស៊ីវិល និង បៀវត្សកងកម្លាំងប្រដាប់អាវុធ
- បង្កើនបៀវត្ស ប្រកបដោយចីរភាព ផ្អែកលើស្ថានភាពនៃកំណើនសេដ្ឋកិច្ច និង លទ្ធភាពទ្រទ្រង់បាននៃថវិកា។

# ជំពូកទី២៖ កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨

## ២.៤ យុទ្ធសាស្ត្រ

### ២.៤.១ សេវាសាធារណៈ

- ជំរុញឲ្យមានការផ្លាស់ប្តូរទស្សនាទានក្នុងក្របខ័ណ្ឌនៃការផ្តល់សេវាសាធារណៈរបស់មន្ត្រីរាជការពីអ្នកគ្រប់គ្រងទៅជាអ្នកផ្តល់សេវា ព្រមទាំង ផ្តល់តម្លៃដល់អ្នកប្រើប្រាស់សេវា។

- ជំរុញការកែទម្រង់របៀបរបបការងារពីរចនាសម្ព័ន្ធការងារ ទៅជារចនា សម្ព័ន្ធប្រតិបត្តិការដោយលើកកម្ពស់គុណភាពសេវាផ្នែកជួរមុខ ព្រមទាំង បង្កើនសមត្ថភាពផ្នែកទ្រទ្រង់។

# ជំពូកទី២៖ កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨

## ២.៤ យុទ្ធសាស្ត្រ

### ២.៤.២ ការគ្រប់គ្រង និង អភិវឌ្ឍធនធានមនុស្ស

- ធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធការងារក្នុងអង្គភាព និងការគ្រង់គ្រងមន្ត្រី
- ពង្រឹងប្រសិទ្ធភាពនៃដំណើរការអនុវត្តការគ្រប់គ្រងធនធានមនុស្ស
- អនុវត្តប្រព័ន្ធគ្រប់គ្រងគុណផល
- ប្រើប្រាស់ឲ្យកាន់តែប្រសើរឡើងនូវសមត្ថភាពការងារដែលមានស្រាប់ និង អភិវឌ្ឍសមត្ថភាព ការងារថ្មី
- ផ្តល់ការបណ្តុះបណ្តាល និងលើកកម្ពស់គុណភាពបណ្តុះបណ្តាល។

# ជំពូកទី២៖ កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨

## ២.៤ យុទ្ធសាស្ត្រ

### ២.៤.៣ ការកែទម្រង់ប្រព័ន្ធបៀវត្ស និងប្រាក់បន្ថែមផ្សេងៗ

- រៀបចំប្រព័ន្ធចំណាត់ថ្នាក់ និងតារាងសន្ទស្សន៍បៀវត្សថ្មី ព្រមទាំងប្រាក់បំណាច់ មុខងារនិងប្រាក់ឧបត្ថម្ភផ្សេងៗ ដើម្បីគាំទ្រដល់ការបំពេញការងាររបស់មន្ត្រីរាជការ
- កាត់បន្ថយគម្លាតបៀវត្សរវាងបៀវត្សអតិបរមា និងអប្បបរមាឲ្យមកនៅត្រឹមពី ៣ ទៅ ៣.៥ ដង
- រៀបចំសន្ទស្សន៍បៀវត្សមូលដ្ឋាន និងប្រាក់បំណាច់មុខងាររបស់នគរបាលជាតិ យោធិន ឲ្យមានសង្គតិភាពទៅនឹងប្រព័ន្ធបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- ដំឡើងប្រាក់បៀវត្សដោយផ្អែកលើផលិតភាព កំណើនសេដ្ឋកិច្ច និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។


បម្រើប្រជាជន
ឲ្យកាន់តែល្អ
ប្រសើរឡើង
ធនធានមនុស្ស
សេវាសាធារណៈ
ហិរញ្ញវត្ថុ
វប្បធម៌សេវាសាធារណៈ
ភាពឆ្លើយតប
ប្រសិទ្ធភាពនិងប្រសិទ្ធផល
ជំនឿទុកចិត្ត
ការចូលរួម
ឆន្ទៈម្ចាស់ការ

# ជំពូកទី២៖ កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨

## ២.៦ ផែនការសកម្មភាពដែលត្រូវអនុវត្តពីឆ្នាំ ២០១៥-២០១៨

### ២.៦.១ ការពង្រឹងគុណភាព និងប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ

១. រៀបចំបង្កើត និងដាក់ឲ្យអនុវត្តប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈក្នុងវិស័យនីមួយៗ

២. ធ្វើបច្ចុប្បន្នភាពព័ត៌មានសេវាសាធារណៈ ព្រមទាំងជំរុញការបណ្តុះបណ្តាល និងផ្សព្វផ្សាយអំពីសេវាសាធារណៈ ជាពិសេស តាមប្រព័ន្ធអេឡិចត្រូនិច

៣. កែលម្អនីតិវិធី និងយន្តការក្នុងការផ្តល់សេវាសំខាន់ៗ ដែលពាក់ព័ន្ធផ្ទាល់ទៅនឹងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដូចជា វិស័យសុខាភិបាល អប់រំ ពាណិជ្ជកម្ម សាធារណៈការ និងដឹកជញ្ជូន ការចុះបញ្ជីដីធ្លី និងសំណង់ ការលក់សំបុត្រ អត្រានុកូលដ្ឋាន លិខិតឆ្លងដែន និងអត្តសញ្ញាណប័ណ្ណជាដើម

៤ .ធ្វើការវិភាគមុខងារ និងលំហូរការងារសម្រាប់សេវាសាធារណៈ ដែលមានផលប៉ះពាល់ផ្ទាល់ លើមន្ត្រីរាជការ ដូចជាការបើកផ្តល់ប្រាក់បេសកកម្ម ប្រាក់ឧបត្ថម្ភ និងសោធន៍និវត្តន៍ដល់និវត្តជន ជាដើម

# ជំពូកទី២៖ កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨

## ២.៦ ផែនការសកម្មភាពដែលត្រូវអនុវត្តពីឆ្នាំ ២០១៥-២០១៨

### ២.៦.១ ការពង្រឹងគុណភាព និង ប្រសិទ្ធភាពក្នុងការផ្តល់ សេវាសាធារណៈ

**៥.** កែលម្អនីតិវិធី និងយន្តការផ្តល់សេវាសាធារណៈ ដែលអនុវត្តដោយស្ថាប័នមានសមត្ថកិច្ច ឬ ស្ថាប័នទទួលសមត្ថកិច្ច តាមរយៈយន្តការផ្សេងៗ ដូចជា គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ ទីភ្នាក់ងារប្រតិបត្តិការពិសេស និង ការិយាល័យច្រកចេញចូលតែមួយជាដើម

**៦.** រៀបចំដាក់ឲ្យដំណើរការនូវយន្តការផ្តល់ព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវាសាធារណៈ នៅតាមយន្តការផ្តល់សេវាសាធារណៈទាំងអស់ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

**៧.**សិក្សា និងជំរុញការផ្តល់សេវាសាធារណៈតាមប្រព័ន្ធព័ត៌មានវិទ្យា។

# ជំពូកទី២៖ កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨

## ២.៦ ផែនការសកម្មភាពដែលត្រូវអនុវត្តពីឆ្នាំ ២០១៤-២០១៨

### ២.៦.២ ការគ្រប់គ្រង និង ការអភិវឌ្ឍធនធានមនុស្សនិងស្ថាប័ន

១. រៀបចំ និងដាក់ឲ្យអនុវត្តក្របខ័ណ្ឌគតិយុត្តនៃការបណ្តុះបណ្តាលជាកាតព្វកិច្ចសម្រាប់មន្ត្រីរាជការស៊ីវិល និងកែលម្អកម្មវិធីបណ្តុះបណ្តាល និងការអភិវឌ្ឍធនធានមនុស្សនៅតាមក្រសួងស្ថាប័ន ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

២. រៀបចំអង្គមន្ត្រីរាជការស៊ីវិល មុខតំណែងនិងការពិពណ៌នាមុខតំណែងក្នុងមុខងារសាធារណៈ

៣. រៀបចំ និងដាក់ឲ្យអនុវត្តប្រព័ន្ធគ្រប់គ្រងគុណផល និងប្រព័ន្ធលើកទឹកចិត្តនៅតាមក្រសួង ស្ថាប័ន ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

៤. កែលម្អរចនាសម្ព័ន្ធគ្រប់គ្រង បែបបទការងារ និងការអភិវឌ្ឍសមត្ថភាពរបស់នាយកដ្ឋាន ឬអង្គភាពធនធានមនុស្ស នៅតាមក្រសួង ស្ថាប័ន ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

# ជំពូកទី២៖ កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨

## ២.៦ ផែនការសកម្មភាពដែលត្រូវអនុវត្តពីឆ្នាំ ២០១៤-២០១៨

### ២.៦.២ ការគ្រប់គ្រង និង ការអភិវឌ្ឍធនធានមនុស្សនិងស្ថាប័ន

៥. កែលម្អនីតិវិធី និងបែបបទ នៃការគ្រប់គ្រងធនធានមនុស្ស នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

៦. ធ្វើការវិភាគមុខងារ និងត្រួតពិនិត្យប្រតិបត្តិការឡើងវិញ នៅតាមក្រសួង ស្ថាប័ន ថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ

៧. អភិវឌ្ឍ និងពង្រីកការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា សម្រាប់ការគ្រប់គ្រងធនធានមនុស្ស នៅតាមក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

៨. បញ្ជ្រាបយេនឌ័រក្នុងវិស័យមុខងារសាធារណៈ។

# ជំពូកទី២៖ កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨

## ២.៦ ផែនការសកម្មភាពដែលត្រូវអនុវត្តពីឆ្នាំ ២០១៤-២០១៨

### ២.៦.៣ ការកែទម្រង់ប្រព័ន្ធបៀវត្ស និងប្រាក់លាភការផ្សេងៗ

១. រៀបចំ និងដាក់ឲ្យអនុវត្តការបើកផ្តល់ប្រាក់បៀវត្សជូនមន្ត្រីរាជការតាមធនាគារ ដោយប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិច

២. រៀបចំដាក់បញ្ចូលប្រាក់បៀវត្សមន្ត្រីជាប់កិច្ចសន្យា ទៅក្នុងប្រព័ន្ធទិន្នន័យរួមរបស់មន្ត្រីរាជការ និងដាក់ឲ្យបើកប្រាក់តាមប្រព័ន្ធធនាគារ

៣. រៀបចំ និងកែសម្រួលប្រព័ន្ធបៀវត្សមន្ត្រីរាជការស៊ីវិល ដោយផ្តោតលើការកែសម្រួលបៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារ និងប្រាក់ឧបត្ថម្ភផ្សេងៗសម្រាប់មន្ត្រីរាជការស៊ីវិលទាំងអស់ឲ្យមានសង្គតិភាព សមធម៌និងឆ្លើយតបនឹងអាទិភាពរបស់រាជរដ្ឋាភិបាល ព្រមទាំងគាំទ្រដល់ផលិតភាព និងការផ្តល់សេវា

# ជំពូកទី២៖ កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨

## ២.៦ ផែនការសកម្មភាពដែលត្រូវអនុវត្តពីឆ្នាំ ២០១៤-២០១៨

### ២.៦.៣ ការកែទម្រង់ប្រព័ន្ធបៀវត្ស និង ប្រាក់លាភការផ្សេងៗ

៤. រៀបចំកែសម្រួលសន្ទស្សន៍បៀវត្សមូលដ្ឋាន និងប្រាក់បំណាច់មុខងារ អតិបរមា និងអប្បបរមារបស់នគរបាលជាតិ និង យោធិន ឲ្យស្របជាមួយនឹងមន្ត្រីរាជការស៊ីវិល

៥. រៀបចំ និងដាក់ឲ្យដំណើរការប្រព័ន្ធព្យាករណ៍ថវិកាសម្រាប់បន្ទុកបុគ្គលិក។

# ជំពូកទី៣៖ យន្តការគាំទ្រ និងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិ

៣.១ យន្តការគាំទ្រ និងការអនុវត្តកម្មវិធីជាតិ

៣.២ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត

៣.៣ សូចនាការគោលនៃសមិទ្ធកម្មរបស់កម្មវិធីជាតិ

# ជំពូកទី៣៖ យន្តការអនុវត្ត និងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

## ៣.១ យន្តការគាំទ្រ និងការអនុវត្តកម្មវិធីជាតិ

**១. ក្រសួងមុខងារសាធារណៈ និងគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ**

អ្នកដឹកនាំ សម្របសម្រួល និង តាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត

**២. ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ**

- ភាពជាម្ចាស់ គណនេយ្យភាព និងការទទួលខុសត្រូវលើការងារកែទម្រង់រដ្ឋបាលសាធារណៈ ក្នុងដែនសមត្ថកិច្ច និងជំនាញរបស់ខ្លួន
- អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ឬ អគ្គលេខាធិការដ្ឋាន ឬ អង្គភាពទទួលបន្ទុករដ្ឋបាលនិងធនធានមនុស្ស និងគណៈអភិបាលរាជធានី ខេត្ត

**៣. កិច្ចសហការយ៉ាងជិតស្និទ្ធរបស់លេខាធិការដ្ឋានកំណែទម្រង់ទាំង៣**

- យន្តការស្ថាប័នរួមក្នុងកម្រិតបច្ចេកទេស
- ផ្សារភ្ជាប់គ្នារវាងសកម្មភាពកែទម្រង់អន្តរវិស័យ និងគាំទ្រគ្នាទៅវិញទៅមក
- ក្របខ័ណ្ឌនៃការកៀរគរនិងប្រើប្រាស់ហិរញ្ញវត្ថុនិងបច្ចេកទេស។

# ជំពូកទី៣៖ យន្តការអនុវត្ត និងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

## ៣.១ យន្តការគាំទ្រ និងការអនុវត្តកម្មវិធីជាតិ

### ៤. យុទ្ធវិធីក្នុងការអនុវត្តកម្មវិធីជាតិ

- ការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងកម្រិតបច្ចេកទេស តាំងពីដំបូងរហូតដល់ពេលអនុវត្ត (**ពីក្រោមឡើងទៅលើ**) => កម្រិតនយោបាយគាំទ្រ
- ក្រុមការងារបច្ចេកទេសរបស់រាជរដ្ឋាភិបាល ឬ ក្រុមការងារបច្ចេកទេសអន្តរក្រសួង ដើម្បីអនុវត្តការងារ ឬ ដោះស្រាយបញ្ហានីមួយៗ តាមការចាំបាច់
- ចង្កោមសកម្មភាពត្រូវអនុវត្តជា**គម្រោងតូចៗ**ដែលមានការកំណត់អំពីសកម្មភាពការងារលម្អិត ពេលវេលាដែលត្រូវអនុវត្ត ចំនួនអ្នកអនុវត្តគម្រោង ការពិពណ៌នាអំពីមុខតំណែង លទ្ធផលរំពឹងទុក ការប៉ាន់ប្រមាណតម្លៃ ប្រភពធនធាន សូចនាករគន្លឹះ និង យន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃ។
- (១) គ្រប់គ្រង (២) ពិនិត្យ វិភាគនិងកែតម្រូវអភិក្រមនីមួយៗ (៣) ផ្សព្វផ្សាយអភិក្រមដែលកែតម្រូវរួច និង(៤)បច្ចេកវិទ្យាព័ត៌មាននីយកម្ម។

# ជំពូកទី៣៖ យន្តការអនុវត្ត និងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

## ៣.២ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត

### ១. យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ៖ ក្រសួង ម.ស និង គ.ក.រ

- ត្រូវតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត ដោយផ្អែកលើ**សូចនាករគោល**នៃសមិទ្ធកម្មរបស់កម្មវិធីជាតិ
- ត្រូវត្រួតពិនិត្យនិងវាយតម្លៃ**រាល់ដំណាច់ឆ្នាំ អំពីវឌ្ឍនភាព បញ្ហាប្រឈម និងរកដំណោះស្រាយ** ព្រមទាំងកំណត់អាទិភាពនិងទិសដៅអនុវត្តបន្ត

### ២. យន្តការ និងប្រព័ន្ធរាយការណ៍

- ក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ត្រូវរាយការណ៍**ប្រចាំត្រីមាស** អំពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ក្នុងវិស័យនិងដែនសមត្ថកិច្ចរៀងៗខ្លួន
- ក្រសួង ម.ស និង គ.ក.រ ត្រូវ**រាយការណ៍ប្រចាំឆ្នាំ ជូនរាជរដ្ឋាភិបាល** ដើម្បីពិនិត្យ និងអនុម័តមុននឹងផ្សព្វផ្សាយជាសាធារណៈ

# ជំពូកទី៣៖ យន្តការអនុវត្ត និងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

## ៣.៣ សូចនាករគោលនៃសមិទ្ធកម្មរបស់កម្មវិធីជាតិ

១. មុខងារសាធារណៈទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំជាអង្គវិជ្ជាជីវៈ និងមានការកំណត់មុខតំណែង និងការពិពណ៌នាតំណែងច្បាស់លាស់

២. ការកសាងសមត្ថភាពមន្ត្រីរាជការមានប្រសិទ្ធភាព និងមានប្រព័ន្ធវាយតម្លៃច្បាស់លាស់

៣. ប្រព័ន្ធបៀវត្សមន្ត្រីរាជការមានសង្គតិភាព សមធម៌ និងគាំទ្រផលិតភាព

៤. ការវិភាគមុខងារ និងការត្រួតពិនិត្យប្រតិបត្តិការឡើងវិញរបស់ក្រសួង ស្ថាប័ន ត្រូវបានអនុវត្ត និងធ្វើវិចារណកម្ម

៥. ប្រព័ន្ធគ្រប់គ្រងគុណផលការងារ និងប្រព័ន្ធលើកទឹកចិត្ត ត្រូវបានដាក់ឲ្យដំណើរការ

# ជំពូកទី៣៖ យន្តការអនុវត្ត និងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

## ៣.៣ សូចនាករគោលនៃសមិទ្ធកម្មរបស់កម្មវិធីជាតិ

៦. ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ត្រូវបានដាក់ឲ្យអនុវត្ត

៧. ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងធនធានមនុស្ស ត្រូវបានដាក់ឲ្យអនុវត្តនៅគ្រប់ក្រសួង ស្ថាប័ន

៨. ការផ្តល់សេវាសាធារណៈតាមប្រព័ន្ធព័ត៌មានវិទ្យា ត្រូវបានពង្រីកជាលំដាប់

៩. ការកើនឡើងនៃមន្ត្រីរាជការជាស្ត្រីក្នុងមុខងារសាធារណៈ និងក្នុងកម្រិតគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

# ជំពូកទី៤៖ ប្រភពថវិកា និងធនធានហិរញ្ញវត្ថុ

## ប្រភពថវិកា និងធនធានហិរញ្ញវត្ថុ

១. ថវិកាជាតិ

២. ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ ឬ

៣. ប្រភពថវិកាស្របច្បាប់ដទៃទៀត។

# ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន

- កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨ មានលក្ខណៈគ្រប់ជ្រុងជ្រោយ ប្រាកដនិយម រួមជាមួយនឹងភាពជាអ្នកដឹកនាំ ភាពម្ចាស់ការ ការប្តេជ្ញាចិត្ត ការសម្របសម្រួល ការចូលរួមពីអ្នកពាក់ព័ន្ធទាំងអស់ ជាពិសេស បទពិសោធន៍ និងសមត្ថភាពអនុវត្តការងាររបស់ក្រសួង ស្ថាប័ន និងមន្ត្រីរាជការ ទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ
- យន្តការស្ថាប័នទទួលខុសត្រូវច្បាស់លាស់ លើអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈ និងយន្តការសម្របសម្រួលជាមួយការដ្ឋានកែទម្រង់ដទៃទៀត
- រាជរដ្ឋាភិបាល សង្ឃឹមនឹងអនុវត្តបានសម្រេចជោគជ័យតាមគោលដៅ និងយុទ្ធសាស្ត្រនៃកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨ ក៏ដូចជាយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល។

សូមអរគុណ!